# មេរៀនទី៣១៖ សុបិន្តរបស់យ៉ូសែប

## លោកុប្បត្តិ ៣៧៖១-១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/-k9nf92Com0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/ntxwbyyJy7Y

**គោលបំណង៖** ព្រះចង់ឱ្យយើងស្រលាញ់គ្រួសាររបស់យើង

**ខគម្ពីរចងចាំ៖ អេភេសូ ៦៖១** *"ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ។"*

**ចំរៀង** ( *យូធូបលីង* )៖
1. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY
2. ក្តីស្រលាញ់នៃព្រះផ្អែមហើយអស្ចារ្យ https://youtu.be/W7hfRd0undE
3. សូមព្រះអង្គអង្រួនយើង https://youtu.be/7KoUcleDz9c

## ១. អធិស្ឋាន

## ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ៣. ល្បែងកំសាន្ត *"ចាប់ក្រុមតាមលេខ"*




១. ឱ្យកុមារៗរាំតាមភ្លេង ហើយពេលដែលគ្រូហៅ លេខ កុមារៗត្រូវតែ ត្រៀមខ្លួនរត់រកគ្នាឲ្យបានគ្រប់តាមចំនួនលេខដែល គ្រូហៅ។

២. ឧទាហរណ៍ៈបើគ្រូហៅលេខ៣កុមារត្រូវចាប់គ្នា៣។

៣. លេងហ្គេមនេះម្តងហើយ ម្តងទៀត រហូតដល់កុមារសប្បាយរីករាយជាមួយហ្គេមនេះ។

## ៤. ការណែនាំមេរៀន

ព្រះគម្ពីរគឺជាសំបុត្រនៃសេចក្តីស្រលាញ់ ដែលព្រះផ្ញើមកយើង។ តាមរយៈព្រះគម្ពីរ យើងបានដឹងពីព្រះវិញ្ញាណបរិសុទ្ធដ៏ពិត ដឹងពីការអស្ចារ្យទាំងឡាយ ស្គាល់ព្រះអទិករដែលជាអ្នកមករកមនុស្សដោយសេចក្តីស្រលាញ់ តាំងពីថ្ងៃដំបូងដែលព្រះអង្គបានបង្កើតយើងមក។ យើងបានដឹងថាព្រះអង្គស្រលាញ់យើង ហើយគ្មានសេចក្តីស្រលាញ់ណាប្រៀបស្មើនិងក្តីស្រលាញ់ទ្រង់ឡើយ។ ក្តីស្រលាញ់ ទ្រង់គឺគ្រប់លក្ខណ៍ អត់ធ្មត់ ចិត្តល្អ យោគយល់ លះបង់ បរិសុទ្ធ និងមិនដែលបោះបង់ឡើយ។ ហើយអ្វីដែលល្អជាងគេនោះគឺក្តីស្រលាញ់របស់ព្រះជាអំណោយ ដែលទ្រង់ប្រទានមកឱ្យយើងមុនពេលយើងបានស្គាល់ទ្រង់ទៅ ទៀត។ ក្តីស្រលាញ់ទ្រង់បានចាក់បង្ហូរមកដល់យើងតាំងពីយើងនៅជាមនុស្សមាន បាបនៅឡើយ (**រ៉ូម៖៥:៨**)។ មានន័យថាព្រះបានស្រលាញ់យើងគឺពេលដែលយើងនៅជា មនុស្សអាក្រក់នៅឡើយ។ ក្តីស្រលាញ់របស់ទ្រង់អស្ចារ្យណាស់ ព្រះចង់ឱ្យយើងចែករំលែកក្តីស្រលាញ់របស់ទ្រង់ ដល់ក្រុមគ្រួសារ របស់យើងដែរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលខ្លះនៅក្នុងគ្រួសារអាចមានក្ដីស្រលាញ់ ហើយមានទំនាក់ទំនងជាមួយគ្នាបានយ៉ាងល្អ ហើយពេលខ្លះទៀតយើងក៏អាចនឹងឈ្លោះប្រកែកគ្នា មិនសប្បាយចិត្តជាមួយគ្នា ឬក៏អួតអាងដាក់គ្នាក៏មាន។ទោះបីជាយើងមិនបានបង្ហាញក្ដីស្រលាញ់គ្រប់លក្ខណ៍ដាក់គ្នាក៏ដោយ ក៏ព្រះនៅតែបង្ហាញក្ដីស្រលាញ់គ្រប់លក្ខណ៍ របស់ទ្រង់ចំពោះយើងដែរ។ ព្រះតែងតែស្រលាញ់យើងដោយគ្រប់លក្ខណ៍ មិនថាយើងគិតអ្វី ឬប្រព្រឹត្តិបែបណានោះទេ។ ថ្ងៃនេះយើងនឹងទៅស្វែងយល់ពីគ្រួសារមួយនៅក្នុងព្រះគម្ពីរ ដែលបានទទួលក្ដីស្រលាញ់គ្រប់លក្ខណ៍ពីព្រះជាម្ចាស់ ប៉ុន្តែពួកគេមិនបានចែករំលែកក្ដីស្រលាញ់នោះជាមួយគ្នាបានល្អទេ។ ព្រះស្រលាញ់យ៉ាកុបដោយក្ដីស្រលាញ់គ្រប់លក្ខណ៍របស់ទ្រង់ តែយ៉ាកុបមិនបានស្រលាញ់ក្រុមគ្រួសារគាត់ឲ្យបានគ្រប់លក្ខណ៍នោះទេ។ យ៉ាកុបបានរស់នៅលើទឹកដីកាណាន ជាមួយកូនៗទាំង១២នាក់របស់គាត់។ គាត់ស្រលាញ់កូនៗរបស់គាត់ទាំងអស់ តែគាត់ស្រលាញ់ពួកគេមិនស្មើគ្នាទេ។

យ៉ូសែបជាកូនប្រុសសំណព្វរបស់យ៉ាកុប។ យ៉ូសែបមានអាយុ១៧ឆ្នាំ ជាកូនទី១១ក្នុងចំណោមកូនទាំង១២ នាក់របស់យ៉ាកុប។ យ៉ូសែបជាកូនដែលកើតពីរ៉ាជែល ជាប្រពន្ធដែលយ៉ាកុបស្រលាញ់ជាងគេ។ រាល់ថ្ងៃយ៉ូសែបទៅឃ្វាលចៀមមួយបងៗ ប៉ុន្តែគាត់ប្រាប់យ៉ាកុបថា បងៗរបស់គាត់ធ្វើការមិនបានល្អទេ។ ក្រៅពីចេះទូរពិតហើយ យ៉ូសែបក៏បានទទួលបានអាវពណ៌ច្រើនពីយ៉ាកុបថែមទៀត។ យ៉ាកុបមិនបាន ឱ្យអាវនេះទៅកូនប្រុសផ្សេងៗទេ។ បងៗរបស់យ៉ូសែបខឹងនឹងគាត់ដោយសារយ៉ូសែបជាកូនសំណព្វ ហើយពួកគេច្រណែនព្រោះពួកគេមិនបានទទួលអាវពណ៌ច្រើនពីឪពុកដូចយ៉ូសែប។ ពួកគេមិនអាចនិយាយពាក្យល្អៗជាមួយប្អូនប្រុសរបស់ពួកគេបានទេ។

យប់មួយយ៉ូសែបបានយល់សប្ដិឃើញរឿងមួយ ហើយគាត់បានប្រាប់បងៗគាត់ពីអ្វីដែលគាត់បានសុបិន្តឃើញនោះ។ គាត់បាននិយាយថា "ខ្ញុំឃើញយើងទាំងអស់គ្នាកំពុងចងកណ្ដាប់ស្រូវនៅវាលស្រែពេលនោះ ស្រាប់តែកណ្ដាប់របស់បងៗបានមកព័ទ្ធជុំវិញកណ្ដាប់ខ្ញុំ ហើយនាំគ្នាក្រាបថ្វាយបង្គំកណ្ដាប់របស់ខ្ញុំ"
បងៗគាត់មិនសប្បាយចិត្តជាមួយការសុបិន្តនេះទេ ព្រោះស្ដាប់ទៅដូចជាយ៉ូសែបគិតថាគាត់ គ្រាន់បើជាងបងៗរបស់គាត់ ហើយបង្ហាញថាយ៉ូសែបនឹងត្រួតត្រាលើពួកបងៗគាត់ ពេលនោះបងៗរបស់គាត់ក៏ចាប់ផ្ដើមស្អប់យ៉ូសែប។

យ៉ូសែបមិនបានយកចិត្តទុកដាក់ជាមួយនិងអារម្មណ៍បងៗរបស់គាត់ទេ។ ក្រោយមកយ៉ូសែបបានសុបិនម្ដងទៀត គាត់បានប្រាប់បងៗ និងឪពុករបស់គាត់ពីសុបិន្តនោះ "យ៉ូសែបបាននិយាយថា៖ ខ្ញុំសុបិន្តឃើញ ព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ១១ដួងបានក្រាបថ្វាយបង្គំខ្ញុំ" ។ ឪពុកគាត់ឆ្ងល់ចំពោះសុបិន្តរបស់ យ៉ូសែប តែបងៗរបស់គាត់វិញមានអារម្មណ៍ខឹងចំពោះយ៉ូសែបរឹតតែខ្លាំងឡើង។ ព្រះស្រលាញ់យ៉ាកុបនិងក្រុមគ្រួ-សាររបស់គាត់ដោយក្ដីស្រលាញ់គ្រប់លក្ខណ៍របស់ទ្រង់។ យ៉ាកុបក៏ស្រលាញ់ព្រះដែរ ប៉ុន្តែគាត់មិនបានស្រលាញ់ព្រះ និងកូនៗរបស់របស់គាត់ជាមួយនឹងក្ដីស្រលាញ់ គ្រប់លក្ខណ៍ទេ។ ហើយកូនៗរបស់គាត់មិនបានស្រលាញ់គ្នាទៅវិញទៅមកជាមួយ នឹងក្ដីស្រលាញ់របស់ព្រះដែរ ពួកគេទាំងអស់គ្នាគឺមិនមានក្ដីសុខនោះទេ។

នៅសប្ដាហ៍ក្រោយយើងនឹងរៀនបន្ថែមទៀតពីអ្វីដែលនឹងកើតឡើង នៅពេលដែលសមាជិកគ្រួសារមិនបានស្រលាញ់គ្នាទៅវិញទៅមកដូច្នេះ។

### ៦. សំនួរពិភាក្សា

១. តើយ៉ូសែបមានបងប្អូនប៉ុន្មាននាក់? *(១១នាក់)*

២. តើអ្នកណាជាកូនសំណព្វរបស់យ៉ាកុប? *(យ៉ូសែប)*

៣. តើយ៉ាកុបបានឱ្យអ្វីទៅយ៉ូសែប? *(អាវពណ៌ច្រើន)*

៤. ហេតុអ្វីបានជាបងៗស្អប់យ៉ូសែប? *( បងៗច្រណែនយ៉ូសែប)*

៥.តើកូនៗស្រលាញ់ប៉ាម៉ាក់ និងបងប្អូនកូនដែរឬទេ? *(ទៅដល់ផ្ទះកូនត្រូវនិយាយថាខ្ញុំស្រលាញ់ ឪពុកម្តាយ និងបងប្អូន)*

### ៧. ខគម្ពីរចងចាំ

**អេភេសូ ៦៖១** *"ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើដូច្នោះទើបបានត្រូវ"។*

- សូមគ្រូជួយក្មេងៗឱ្យទន្ទេញខគម្ពីរនេះ

### ៨. ហាត្ថកម្ម

១. ឱ្យកុមារកាត់ក្រដាសធ្វើជារូបបេះដូងហើយសរសេរពាក្យថា "ខ្ញុំស្រលាញ់……."

២. ឱ្យកុមារផាត់ពណ៌អាវពណ៌ច្រើនរបស់យ៉ូសែប

### ៩. ចំរៀង

សូមរើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស

### ១០.អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ**: ( **សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន** )
នៅពេលដែលយើងដើរតាមព្រះគ្រីស្ទហើយរីកលូតលាស់នៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់យើងពិតជាចង់បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់នៅក្នុងគ្រួសាររបស់យើង។ កូនៗរបស់យ៉ាកុបទាំងអស់ត្រូវការសេចក្តីស្រលាញ់និងចង់ក្លាយជាកូនសំណព្វរបស់ឪពុកខ្លួន។ សូមអានខគម្ពីរ លោកុប្បត្តិ ៣៧៖៣-៤ ម្តងទៀត។ តើក្តីស្រលាញ់លំអៀងរបស់យ៉ាកុបចំពោះយ៉ូសែបវាធ្វើឲ្យប៉ះពាល់ដល់កូនៗផ្សេងទៀតយ៉ាងណាខ្លះ? ដូចដែលអ្នកបង្រៀនកុមារៗដែរ សូមចាំថាសិស្សគ្រប់រូបគឺសុទ្ធតែពិសេស ហើយពួកគេចង់បានការស្រលាញ់ពីគ្រូរបស់ពួកគេ។ ក្នុងសប្តាហ៍នេះសូមបង្ហាញក្តីស្រលាញ់ដ៏វិសេសនោះទៅកាន់សិស្សៗរបស់អ្នក។

# អាវពណ៌ច្រើនរបស់យ៉ូសែប



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________